# សិទ្ធិបោះឆ្នោត

## បុគ្គលដែលមានទោសឧក្រិដ្ឋពីមុន

## តើអ្នកបានធ្លាប់ជាប់ពន្ធនាគារទេ?
## អ្នកអាចមានសិទ្ធិបោះឆ្នោត។

### អ្នកអាចមានសិទ្ធិបោះឆ្នោត ប្រសិនបើអ្នក៖

- **នៅក្នុងមន្ទីរឃុំឃាំងក្នុងតំបន់៖**
  - — កំពុងជាប់បទមជ្ឈិម
  - — កំពុងជាប់ពន្ធនាគារក្នុងករណីបទឧក្រិដ្ឋ
  - — ព្រោះការជាប់ពន្ធនាគារ គឺជាលក្ខខណ្ឌនៃការព្យួរទោស ដោយមានលក្ខខណ្ឌ (បទមជ្ឈិម ឬបទឧក្រិដ្ឋ)
  - — កំពុងរង់ចាំការកាត់សេចក្តី
- **ស្ថិតក្នុងការតាមដាន**
- **ស្ថិតក្នុងដំណាក់កាលដោះលែង**
- **ស្ថិតក្នុងការត្រួតពិនិត្យជាកាតព្វកិច្ច**
- **ស្ថិតក្នុងការត្រួតពិនិត្យរបស់សហគមន៍ក្រោយត្រូវបានដោះលែង**
- **ស្ថិតក្នុងការដោះលែងដែលគ្រប់គ្រងដោយសហព័ន្ធ**
- **បុគ្គលដែលជាប់ការការវិនិច្ឆ័យទោសក្រោមការគ្រប់គ្រងរបស់តុលាការក្នុងករណីអនីតិជន**

### លក្ខខណ្ឌសិទ្ធិទទួលបាន

អ្នកអាចចុះឈ្មោះបោះឆ្នោត និងបោះឆ្នោតបាន ប្រសិនបើអ្នក៖

- ជាពលរដ្ឋអាមេរិក និងជាអ្នករស់នៅរដ្ឋកាលីហ្វ័រញ៉ា
- មានអាយុចាប់ពី 18 ឆ្នាំឡើងទៅនៅថ្ងៃបោះឆ្នោត
- បច្ចុប្បន្នមិនជាប់ពន្ធនាគាររដ្ឋ ឬសហព័ន្ធសម្រាប់ការផ្តន្ទាទោសពីបទឧក្រិដ្ឋ និង
- បច្ចុប្បន្នមិនត្រូវបានតុលាការរកឃើញថាអសមត្ថភាពខាងផ្លូវចិត្តក្នុងការបោះឆ្នោត។

**ស្កេនកូដ QR ដើម្បីចុះឈ្មោះបោះឆ្នោត**

### សិទ្ធិបោះឆ្នោតរបស់អ្នក

- ប្រសិនបើអ្នកជាប់ពន្ធនាគារ ហើយអ្នកមានសិទ្ធិបោះឆ្នោត អ្នកមានសិទ្ធិទទួលបានបណ្ណចុះឈ្មោះអ្នកបោះឆ្នោត។
- ប្រសិនបើអ្នកកំពុងជាប់ពន្ធនាគាររដ្ឋ ឬសហព័ន្ធសម្រាប់ការកាត់ទោសពីបទឧក្រិដ្ឋនៅក្នុងពន្ធនាគាររដ្ឋ ពន្ធនាគារសហព័ន្ធ ឬមន្ទីរឃុំឃាំងក្នុងតំបន់ សិទ្ធិបោះឆ្នោតរបស់អ្នកត្រូវបានស្តារឡើងវិញ នៅពេលដែលអ្នកបានបញ្ចប់អាណត្តិរបស់អ្នក។
  - — ខោនធីរបស់អ្នកនឹងធ្វើការជូនដំណឹងដែលបញ្ជាក់ថា អ្នកអាចចុះឈ្មោះ ឬចុះឈ្មោះបោះឆ្នោតឡើងវិញបាន។

### របៀបចុះឈ្មោះបោះឆ្នោត

- អ្នកអាចស្នើសុំបណ្ណចុះឈ្មោះអ្នកបោះឆ្នោតជាក្រដាសពីរដ្ឋលេខាធិការ ឬការិយាល័យ បោះឆ្នោតប្រចាំខោនធីរបស់អ្នក។
- បណ្ណចុះឈ្មោះអ្នកបោះឆ្នោត និងឯកសារបោះឆ្នោតមានជាភាសាអង់គ្លេស ចិន ហិណ្ឌី ជប៉ុន ខ្មែរ កូរ៉េ អេស្ប៉ាញ តាកាឡុក ថៃ និងវៀតណាម។
- អ្នកអាចុះឈ្មោះតាមអ៊ីនធឺណិតតាមរយៈ: registertovote.sos.ca.gov **ឬតាមការស្កេនកូដ QR ខាងលើ។**

## សម្រាប់ព័ត៌មានបន្ថែមអំពីការស្តារសិទ្ធិរបស់អ្នកឡើងវិញ ចូលទៅកាន់៖ votingrightsrestored.sos.ca.gov

VOTE CALIFORNIA
www.sos.ca.gov

**Shirley N. Weber, Ph.D.**
California Secretary of State

## បុគ្គលដែលរងផលប៉ះពាល់ដោយការជាប់ឃុំឃាំង/ មិនអាចបោះឆ្នោតបានទេនៅពេលនេះ

បច្ចុប្បន្នកំពុងជាប់ពន្ធនាគាររដ្ឋ ឬសហព័ន្ធសម្រាប់ការកាត់ទោសពីបទឧក្រិដ្ឋ និងដាក់ពន្ធនាគារនៅក្នុង៖

- ពន្ធនាគាររដ្ឋ
- ពន្ធនាគារសហព័ន្ធ
- មន្ទីរឃុំឃាំងក្នុងតំបន់*

** ក្រមព្រហ្មទណ្ឌរដ្ឋកាលីហ្វ័រញ៉ាលេខ 2910 អនុញ្ញាតឱ្យក្រសួងកែតម្រូវ និងស្តារនីតិសម្បទាប្រចាំរដ្ឋកាលីហ្វ័រញ៉ា (California Department of Corrections and Rehabilitation, CDCR) ធ្វើកិច្ចព្រមព្រៀងជាមួយរដ្ឋាភិបាលក្នុងតំបន់ ដើម្បីដាក់អ្នកទោសនៅក្នុងមន្ទីរឃុំឃាំងក្នុងតំបន់។ បុគ្គលដែលជាប់ពន្ធនាគាររដ្ឋ ដែលស្ថិតនៅក្នុងមន្ទីរឃុំឃាំងក្នុងតំបន់ ក្រោមកាលៈទេសៈទាំងនេះ មិនត្រូវបានអនុញ្ញាតឱ្យចុះឈ្មោះ និងបោះឆ្នោតឡើយ។ បុគ្គលម្នាក់នៅក្នុងមន្ទីរឃុំឃាំងក្នុងតំបន់ ដែលកំពុងរង់ចាំការផ្ទេរទៅពន្ធនាគាររដ្ឋ ឬសហព័ន្ធបន្ទាប់ពីការកាត់ទោសពីបទឧក្រិដ្ឋ មិនត្រូវបានអនុញ្ញាតឱ្យចុះឈ្មោះ និងបោះឆ្នោតឡើយ។*

## សំណួរ និងធនធាន

ប្រសិនបើអ្នកមិនច្បាស់ថាតើសាលក្រមប្រភេទណាដែលអ្នកកំពុងជាប់ពិរុទ្ធនោះទេ សូមសាកសួរបុគ្គលិកនៅមណ្ឌលកែប្រែរបស់អ្នក។

សម្រាប់ធនធានបន្ថែម សូមទាក់ទងការិយាល័យបោះឆ្នោតប្រចាំខោនធីក្នុងតំបន់របស់អ្នក ឬទាក់ទងរដ្ឋលេខាធិការនៃរដ្ឋកាលីហ្វ័រញ៉ា។

ដើម្បីស្វែងរកធនធានបន្ថែមអំពីការបោះឆ្នោតនៅលើគេហទំព័ររបស់រដ្ឋលេខាធិការ សូមចូលទៅកាន់៖ sos.ca.gov។

សម្រាប់ព័ត៌មានអំពីការបោះឆ្នោតតាមមណ្ឌល សូមចូលទៅកាន់៖ sos.ca.gov/elections/voting-resources/county-elections-offices។

**ស្កេនកូដ QR សម្រាប់ការិយាល័យខោនធី ក្នុងតំបន់**

## ត្រូវបានដោះលែងពីមន្ទីរឃុំឃាំង

- ប្រសិនបើអ្នកត្រូវបានដោះលែងពីមន្ទីរឃុំឃាំង មុនពេលអ្នកទទួលបានសន្លឹកឆ្នោតតាមសំបុត្ររបស់អ្នក អ្នកនៅតែអាចបោះឆ្នោតបាន។ គ្រាន់តែទៅកាន់ទីតាំងបោះឆ្នោតក្នុងខោនធីដែលអ្នកបានចុះឈ្មោះបោះឆ្នោតរបស់អ្នកជាការស្រេច។ អ្នកអាចត្រូវបានស្នើសុំឱ្យបោះឆ្នោតដោយប្រើសន្លឹកឆ្នោតបណ្តោះអាសន្ន។ សម្រាប់ព័ត៌មានបន្ថែមអំពីសន្លឹកឆ្នោតបណ្តោះអាសន្ន សូមចូលទៅកាន់គេហទំព័ររបស់រដ្ឋលេខាធិការស្តីពី ការបោះឆ្នោតបណ្តោះអាសន្ន៖ sos.ca.gov/elections/voting-resources/provisional-voting។
- ប្រសិនបើអ្នកប្តូរឈ្មោះ អាសយដ្ឋានលំនៅឋាន អាសយដ្ឋានសំបុត្រប្រៃសណីយ៍ ឬនិន្នាការគណបក្ស អ្នកត្រូវតែបំពេញពាក្យសុំចុះឈ្មោះអ្នកបោះឆ្នោតថ្មី។ ទោះជាយ៉ាងណាក៏ដោយ ក្នុងរយៈពេល 14 ថ្ងៃមុនការបោះឆ្នោត ជំនួសឱ្យ ការចុះឈ្មោះឡើងវិញ អ្នកអាចដាក់សំណើជាលាយលក្ខណ៍អក្សរទៅកាន់មន្ត្រីបោះឆ្នោតខោនធីរបស់អ្នក ដើម្បីផ្លាស់ប្តូរអាសយដ្ឋាន ឬនិន្នាការគណបក្សរបស់អ្នក។

## រដ្ឋលេខាធិការរដ្ឋកាលីហ្វ័រញ៉ា ខ្សែទូរសព្ទបន្ទាន់សម្រាប់អ្នកបោះឆ្នោត

| | |
|---|---|
| អង់គ្លេស | (800) 345-VOTE (8683) |
| Español / អេស្ប៉ាញ | (800) 232-VOTA (8682) |
| ចិន / 中文 | (800) 339-2857 |
| ហិណ្ឌី / हिन्दी | (888) 345-2692 |
| ជប៉ុន / 日本語 | (800) 339-2865 |
| Khmer / ខ្មែរ | (888) 345-4917 |
| កូរ៉េ / 한국어 | (866) 575-1558 |
| តាកាឡុក | (800) 339-2957 |
| ថៃ / ภาษาไทย | (855) 345-3933 |
| វៀតណាម / Việt ngữ | (800) 339-8163 |
| TTY/TDD | 711 |